សុខ សុត្ថាល សាស្ត្រាចារ្យបរិញ្ញាទស្សនវិជ្ជា

# ទស្សនវិជ្ជា

## សំនួរ ចំលើយ អត្ថាធិប្បាយ



## ថ្នាក់បញ្ចប់

០៥៦.១១

# ទស្សនវិជ្ជា

សំណួរចំលើយតាមអត្ថាធិប្បាយ

LIBRARY
BUDDHIST INSTITUTE
២៥០៤/ពិ

សៀវភៅដែលសិស្សថ្នាក់ទីបញ្ចប់មិនគួរបំភ្លេចគឺ

## រូបវិទ្យា លំហាត់ជ្រើសរើស

របស់

លោកគ្រូ ឡៅ ស៊ាង ហ៊ុង
សាស្ត្រាចារ្យបរិញ្ញា រូបវិទ្យា វិទ្យាល័យភ្នំពេញ

សៀវភៅនេះមាន

— តារាងរូបមន្ត
— លំហាត់ជាងហាសិប ដកស្រង់ពីការប្រឡងក្នុងប្រទេសនានា
— កំណែ Annales Sciences physiques Série DD' 1973-1974

# បញ្ជីអត្ថបទ

## សំណួរ - ចំលើយ


| | | ទំព័រ |
|---|---|---|
| 1 | អ្វីជាទស្សនវិជ្ជា | 9 |
| 2 - | បញ្ញា | 18 |
| 3 | ការរស់ក្តីកថ្មី | 28 |
| 4 | ល្បិចខួរក្បាលគិតនឹក | 36 |
| 5 - | សង្គមនិងគំនិតសង្គម | 44 |
| 6 . | គណិតវិទ្យា | 53 |
| 7 - | សង្គមរូបធាតុនិងវិតតិសោធន៍ | 62 |
| 8 - | ជីវវិទ្យា | 73 |
| 9 - | មនុស្សវិទ្យា | 80 |
| 10 - | សត្វវិទ្យា | 97 |
| 11 - | ចំណោទនៃពពួកជាតិមនុស្ស | 110 |
| 12 - | ឆន្ទៈ | 115 |
| 13 - | កំណែកណើមកិច្ចនិងកុសល | 119 |
| 14 - | សីលញាណ | 129 |
| 15 - | ចំណុចខុសត្រូវនិងវិធាកវិនិច្ឆ័យ | 135 |
| 16 - | ជីវិតផ្ទាល់ខ្លួនក្នុងពពួកធំ | 145 |
| 17 | សិទ្ធិនិងច្បាប់ | 154 |
| 18 | រដ្ឋសារ | 157 |
| 19 | យុត្តិធម៌និងការគោរពបុគ្គល សម្បូរសតិ | 165 |
| 20 | បញ្ហាសេដ្ឋកិច្ច | 171 |
| 21 | បញ្ហា [illegible] | [illegible] |

# អត្ថាធិប្បាយ


ប្រការទី ១- ទស្សនវិជ្ជានិងវិទ្យាច្បាប់

ប្រការទី ២- គណិតវិទ្យា និង ពិសោធន៍

ប្រការទី ៣- គណិតវិទ្យានិងសច្ចៈ

ប្រការទី ៤- សារៈសំខាន់នៃទស្សនវិជ្ជា

ប្រការទី ៥- គណិតវិទ្យាជាឧបករណ៍របស់ច្បាប់

ប្រការទី ៦- ការពិត (fait) និងទ្រឹស្តី

ប្រការទី ៧- ច្បាប់អំពីសីលវិជ្ជានិងច្បាប់ធម្មជាតិ -

ប្រការទី ៨- វិជ្ជាឯកទេសនៃច្បាប់និងរបៀបមិនទូទៅ

ប្រការទី ៩- តក្កវិជ្ជាជាសីលវិជ្ជានៃគំនិត

ប្រការទី ១០- ទីបញ្ចប់នៃសីលវិជ្ជានិងសុភមង្គល

# ១- អ្វីជាទស្សនវិជ្ជា ?

1 - អ្វីជាទស្សនវិជ្ជា ?

ទស្សនវិជ្ជា គឺ ស្នេហាគតិបណ្ឌិត ។

2 - នរណាជាអ្នកអោយនិយមន័យដូចខាងលើនេះ ?

លោក ពីតាករ ( Pythagore ), អ្នកទស្សនវិជ្ជាក្រិច ។

3 - ចុះចំណែក លោក សូក្រាត (Socrate) យល់យ៉ាងណាដែរចំពោះពាក្យ « ទស្សនវិជ្ជា » នេះ ?

លោកសូក្រាតយល់ថា « ទស្សនវិជ្ជា » គឺ គន់គាន់គតិបណ្ឌិត ព្រោះមនុស្សខ្វះគតិបណ្ឌិត ។

4 - នរណាខ្លះដែលជឿថា មនុស្សមានគតិបណ្ឌិតរួចហើយ ពោលគឺចំណេះជាសាកល ?

ពួក សូភីស » ( Sophiste ) ពួកទស្សនវិជ្ជាមួយក្រុមដែលប្រឆាំងនឹងគំនិតរបស់សូក្រាត ។

5 - តើលោកសូក្រាត បានបញ្ជាក់សំដីអ្វីខ្លះទៅលើន័យថា មនុស្សគ្មានចំណេះជាសាកល ?

លោក សូក្រាតបានពោលថា ៖ « ខ្ញុំដឹងតែមួយមុខគឺខ្ញុំគ្មានចេះអ្វីទាំងអស់ »

(Je ne sais qu'nne chose c'est que je ne sais rien)

6- តើអ្វីទៅដែលហៅថា គតិបណ្ឌិតនោះ ?

គឺការយកបញ្ញាទៅពិចារណាព្រឹត្តិការណ៍ ត្រឹមត្រូវទៅលើបញ្ហាទាំងពួង ឬរាយបានបញ្ហាបុគ្គលផ្សេងៗ ឲ្យត្រូវតាម លក្ខណៈប្រកប ដោយវិចារណញ្ញាណ និងភាពយុត្តិធម៌ គឺការចេះប្រមាណនូវគំនិតដ៏ល្អរបស់ខ្លួន ជាមួយនឹងវិធានការត្រឹមត្រូវលើខ្លួនឯង ។

7- តើសូក្រាតបានពោលយ៉ាងដូចម្តេច ចំពោះការពិចារណារបស់មនុស្សតាមបែបទស្សនវិជ្ជា ?

លោកសូក្រាតពោលថា ការពិចារណាតាមបែបទស្សនវិជ្ជា គឺ ភាពស្លាប់ ព្រោះសូក្រាតពិចារណាលើន័យរបស់ជីវិត ។

8- ចុះសិស្សថ្នាក់បញ្ចប់ត្រូវពិចារណា ទៅលើអ្វី ?

សិស្សថ្នាក់បញ្ចប់ត្រូវពិចារណាទៅលើកម្មវត្ថុនៃការសិក្សា របស់គេដូចជា :

១- ឧបករណ៍គំនិតដែលជាផលនៃពិសោធន៍របស់ មនុស្សជំនាន់មុន ។

២- ស្នាដៃគំនិតវិទូរបស់ខ្លួន ។

9- តើយើងត្រូវពិចារណាអ្វីខ្លះជាបឋម ?

យើងត្រូវពិចារណាលើខ្លួនយើងជាមុន បន្ទាប់មកទើបយើង ចាប់ពិចារណា លើអ្វីៗដែលនៅជុំវិញខ្លួនយើង ។

10- កម្មវត្ថុនៃទស្សនវិជ្ជា បើពោលដោយសង្ខេបចែកជា ប៉ុន្មានពួកធំៗ ?

កម្មវត្ថុនៃទស្សនវិជ្ជា ចែកជាបួនភាគធំៗ គឺ :

១ - ចិត្តវិទ្យា - ( Psychologie )

២- តក្កវិជ្ជា - ( Logique )

៣- សីលវិជ្ជា - ( Morale )

៤- បរមត្ថវិជ្ជា ( Métaphysique )

11 - តើសព្វថ្ងៃចែកការសំខាន់បួនរបស់ទស្សនវិជ្ជាស្ថិតនៅ និងអ្វីខ្លះ ?

សព្វថ្ងៃចែកទាំងបួន នៃទស្សនវិជ្ជាស្ថិតនៅលើការគិតគួរបែបគេ ការបង្កើតមនុស្សជាតិថ្មីតែគេវិញគឺ : គុណធម៌

12 - អ្វីទៅហៅថាពុទ្ធិ ?

ពុទ្ធិ (Connaissance) គឺការចេះដឹងដែលកើតឡើងដោយការសិក្សាពីទស្សនវិជ្ជាគ្រប់ផ្នែក ដូចជា ចិត្តវិទ្យា - តក្កវិជ្ជា សីលវិជ្ជា និង បរមត្ថវិជ្ជា ។

13 - អ្វីទៅហៅថាអំពើ ?

អំពើគឺអ្វីៗដែលមនុស្សធ្វើ ហើយជាការទទួលខុសត្រូវពីគ្រប់វិស័យ ដូចជាវិស័យនយោបាយ-សិល្បៈ សីលវិជ្ជា-សង្គមវិទ្យា។ល។

14 - គំនិតទស្សនវិជ្ជាមានលក្ខណៈពិសេសប៉ុន្មាន ?

គំនិតទស្សនវិជ្ជាមានលក្ខណៈពិសេសពីរ គឺ :

១ - គំនិតរិះគិត

២ - គំនិត មនុស្សនិយម

15 - អ្វីទៅហៅថា គំនិតរិះគិត ?

គំនិតរិះគិត គឺ គំនិតដែលតែងតែពិចារណាត្រឹមត្រូវជានិច្ច ។

16 - អ្វីទៅហៅថា គំនិត អព្យាក្រឹត្យ ?

គំនិតអព្យាក្រឹត្យ គឺ គំនិត និយមតាមពិចារណារបស់ខ្លួនឯង និងការពិចារណារបស់អ្នកដទៃផង ។

ឧ - គំនិតយើងក៏ខុស , គំនិតគេក៏ខុស
គំនិតយើងក៏ត្រូវ , គំនិតគេក៏ត្រូវ ។

17 - តើទស្សនវិជ្ជាមានគោលបំណងយ៉ាងណា ?

ទស្សនវិជ្ជាមានបំណងស្វែងរកសច្ចៈដើម្បីបង្ហាញទ្រឹស្តីវិជ្ជា ។ កាលបើបាន « សច្ចៈ » ហើយ ទស្សនវិជ្ជាញ៉ាំងឲ្យប្រតិបត្តិ ។

18 - តើត្រូវចាំបាច់មានទស្សនវិជ្ជា ឬទេ ?

បើកាលណាគេត្រូវការ វិចារណញ្ញាណ និងគតិបណ្ឌិត គេតែងតែត្រូវការទស្សនវិជ្ជាជានិច្ច ។ គេគិតអាចលះបង់ទស្សនវិជ្ជាបានលុះត្រាតែគេអាចលះបង់ចោលនូវបញ្ញាសញ្ចេតនា ។

19 - តើគេអាចនិយាយថា ទស្សនវិជ្ជាជាចំណេះដឹងទូទៅបាន ឬទេ ?

គេអាចនិយាយថា ទស្សនវិជ្ជាជាចំណេះដឹងទូទៅបាន ព្រោះទស្សនវិជ្ជាបានត្រួសត្រាយវិជ្ជាក្នុងលោកផង និងក្រៅលោកផង គឺថាវិជ្ជាទាំងអស់យ៉ាងណាក៏ដោយ ចំណេះដឹងទាំងនោះត្រូវប្រកបដោយវិចារណញ្ញាណផងដែរ ។

20 - តើអ្នកយល់ថា មនុស្សគ្រប់រូបត្រូវមានទស្សនវិជ្ជាផ្ទាល់ខ្លួន ឬទេ ?

មនុស្សជាសត្វដែលបរិភោគនូវសញ្ចេតនាហារ ។ ដូច្នេះ

មនុស្សគ្រប់រូបសុទ្ធតែមានឱកាសស្មើគ្នា បើមនុស្សមានឱកាសស្មើគ្នា មនុស្សតែងត្រូវការវិចារណញ្ញាណ មនុស្សត្រូវតែបានទស្សនវិជ្ជា ដោយខានពុំបាន ។

**21 - ទស្សនវិជ្ជាដែលបាត់បង់បន្តិចម្តងៗ នូវកម្មវត្ថុទាំងឡាយរបស់ខ្លួន តើអាចមានកម្មវត្ថុអ្វីទៀតនឹងយកមកសិក្សា ?**

ថ្វីបើទស្សនវិជ្ជាបានបាត់បង់បន្តិចម្តងៗនូវកម្មវត្ថុទាំងឡាយរបស់ខ្លួនបណ្តាលមកពីការរីកចំរើនលូតលាស់នៃស្យង់ តែទស្សនវិជ្ជាស្ថិតនៅជានិច្ចក្នុងគំនិតរបស់ខ្លួន ព្រមទាំងពុំខ្វះកម្មវត្ថុសម្រាប់សិក្សាឡើយ ។ ព្រោះថា ក្រៅពីទ្រឹស្តីព្រះពុទ្ធដែលបាននិយាយពី រូប-ខន្ធ-ព្រលឹង វិញ្ញាណ, តើស្យង់បានរកឃើញជីវិតក្រោយលោក - និងជីវិតក្រោយរូបហើយឬនៅ ? នេះពុំបានទាំងយកកម្មវត្ថុថ្មីៗ របស់ទស្សនវិជ្ជាដែលមានអ្នកប្រាជ្ញអក្សរសាស្ត្រខ្លះកំពុងត្រូវគេលើកតំកើង ក្រោយដែលបានរកឃើញកម្មវត្ថុនៃទស្សនវិជ្ជាថ្មីៗជាច្រើនដូចជា សាត្រ ( J - P . sartre ) ជាដើម ។

**22 - តើសង្គមយើងសព្វថ្ងៃ ដែលជាសង្គមពោរពេញទៅដោយការរីកចំរើនគ្រប់វិស័យទាំងអស់របស់ស្យង់ ត្រូវការពឹងផ្អែកទៅលើទស្សនវិជ្ជាទៀតឬទេ ?**

ជាមួយគ្នានឹងការជឿនលឿនរបស់ស្យង់ សង្គមលោកសព្វថ្ងៃមិនគ្រាន់តែបានទទួលនូវផលវិបាក បណ្តាលមកពី “ស្យ